00833470

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 08 / 2012
ម៉ោង (Time/Heure): 13:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E211/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២

**ជូនចំពោះ:** **ភាគីនៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **អំពីសេចក្តីជូនដំណឹងរបស់មេធាវីការពារជនជាប់ចោទ នួន ជា មកអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការស្រាវជ្រាវនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារ E211)**

១. កាលពីថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ មេធាវីការពារជនជាប់ចោទ នួន ជា បានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថាខ្លួនមានបំណងធ្វើការស្រាវជ្រាវដោយឯករាជ្យមួយ ដើម្បីផ្ទៀងផ្ទាត់អំពីដំណើរការរក្សាឯកសារ និងប្រភពនៃឯកសារនានារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលសហព្រះរាជអាជ្ញាបានលើកយកមកធ្វើជាសម្អាង (ដូចដែលបានរៀបរាប់ក្នុងឯកសារ E161.1)។ មេធាវីការពារក្តី ក៏បានស្នើផងដែរដល់អង្គជំនុំជម្រះសាលាដំបូងឲ្យជូនដំណឹងទៅខ្លួនវិញ ប្រសិនចេតនាក្នុងការធ្វើដូច្នេះនឹងពុំត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះទេនោះ (E211)។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងនេះកាលពីថ្ងៃ ទី ២៨ ខែ មិថុនា ឆ្នាំ ២០១២ (ឯកសារ E211/1)។

២. ដូចដែលសហព្រះរាជអាជ្ញាបានគូសបញ្ជាក់រួចហើយ ក្រុមខណ្ឌតតិយជននៅ អ.វ.ត.ក ពុំអនុញ្ញាតឱ្យភាគីបើកកិច្ចស៊ើបសួរឡើយ ប៉ុន្តែអនុញ្ញាតឱ្យភាគីពិនិត្យមើលឡើងវិញទៅលើព័ត៌មានដែលមានជាសាធារណៈ[1]។ ហេតុដូច្នេះ ពុំមានអ្វីដែលហាមឃាត់មិនឱ្យមេធាវីការពារក្តីពិនិត្យមើលឡើងវិញនូវព័ត៌មានទាំងឡាយដែលស្ថិតនៅក្នុងមជ្ឈដ្ឋានសាធារណៈ និងស្នើសុំដាក់ឯកសារនេះទៅក្នុងសំណុំរឿង ឬដាក់នៅចំពោះមុខ ក.ស.ច.ស ឬអង្គជំនុំជម្រះសាលាដំបូងដោយអនុលោមតាមពេលវេលាកំណត់នៃការដាក់ឯកសារ។

៣. ការជូនដំណឹងរបស់មេធាវីការពារក្តីនាពេលនេះត្រូវបានធ្វើឡើងបន្ទាប់ពីមានសក្ខីកម្មរបស់សាក្សីចំនួន ០២ រូប មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាគឺលោក វ៉ាន់ថាន់ ពៅដារ៉ា និងលោក ឆាំង យុ ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងកោះហៅដើម្បីឆ្លើយសំណួរនានាពាក់ព័ន្ធនឹងប្រភព និងដំណើរការរក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលត្រូវបានតវ៉ានៅក្នុងសំណុំរឿង ០០២/០១។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងពុំពិនិត្យជារួមឡើងវិញលើបញ្ហាស្តីពីប្រភព និងដំណើររក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឡើយ។ ភាគីទាំងអស់ត្រូវបានផ្តល់ឱកាសដើម្បីសួរសំណួរទៅសាក្សីទាំងនេះនៅពេលដែលពួកគាត់ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយមេធាវីការពារជនជាប់ចោទ នួន ជា ក៏បានប្រើប្រាស់ឱកាសនេះរួចហើយ[2]។ កាលពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធទៅនឹងការជំទាស់របស់មេធាវីការពារក្តីទាំងអស់ពាក់ព័ន្ធនឹងប្រភពនៃឯកសារ ដែលចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារ E185)។ អង្គជំនុំជម្រះក៏បានសម្រេចទៀតថាភាគីពុំចាំបាច់ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងប្រភព និងដំណើររក្សាឯកសារក្នុង

[1] *សូមមើល* ឯកសារ A110/I, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ & ឯកសារ D164/2, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៩, កថាខណ្ឌ ១៤ (ដែលបញ្ជាក់ថាភាគីអាចពិនិត្យមើលឡើងវិញទៅលើឯកសារដែលទទួលបានពីគ្រប់ប្រភពជាសាធារណៈ និងស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតដាក់ឯកសារនេះទៅក្នុងសំណុំរឿងផងដែរ ហើយការស្វែងរកឯកសារទាំងនេះពុំ "ប៉ះពាល់ដល់គោលការណ៍នៃការហាមឃាត់មិនឱ្យភាគីបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងនោះទេ")។ *សូមមើលផងដែរ* ឯកសារនៅចំពោះមុខអង្គបុរេជំនុំជម្រះ, ឯកសារ D365/2/10, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០, កថាខណ្ឌ ២, ១២ & D154/2, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៩, កថាខណ្ឌ ១៤។

[2] ប្រតិចារឹក, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៤៣-១០៥ (វ៉ាន់ថាន់ ពៅដារ៉ា), ប្រតិចារឹក, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៦១-១១៤ និងថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៤-១០៨ (ឆាំង យុ)។

លក្ខណៈជាបុរេលក្ខខណ្ឌនៃការទទួលយកឯកសារនៅចំពោះមុខអង្គជំនុំជម្រះឡើយ ប៉ុន្តែព័ត៌មាននេះអាចជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃរបស់ខ្លួនអំពីតម្លៃជាភស្តុតាងនៃឯកសារនោះ[3]។

៤. ថ្វីបើមេធាវីការពារជនជាប់ចោទ នួន ជា ពុំអាចបើកកិច្ចស៊ើបសួរនៅក្នុងក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក ក៏ដោយ ក៏នៅពេលដែលខ្លួនមានឯកសារដែលស្ថិតនៅក្នុងមជ្ឈដ្ឋានសាធារណៈដែលខ្លួនជឿថាជាឯកសារពាក់ព័ន្ធនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះអំពីភាពអាចជឿជាក់បាន ឬតម្លៃជាភស្តុតាងនៃឯកសារនៅចំពោះមុខអង្គជំនុំជម្រះនោះ មេធាវីមានជម្រើសមួយចំនួនដោយអនុលោមតាមវិធានផ្ទៃក្នុង។ ជាក់ស្តែង មេធាវីអាចដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដោយអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ដោយមានបញ្ជាក់អំពីបញ្ហានានាដែលខ្លួនជឿថាពាក់ព័ន្ធនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះអំពីតម្លៃ និងទម្ងន់ជាភស្តុតាង ដែលត្រូវផ្តល់ទៅឯកសារជាក់លាក់ដែលស្ថិតនៅចំពោះមុខអង្គជំនុំជម្រះ ឬស្នើសុំការទទួលយកឯកសារបន្ថែមដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង លុះត្រាណាលក្ខខណ្ឌតម្រូវនៃអនុវិធាននេះអាចត្រូវបានបំពេញ។ លិខិតជូនដំណឹងនាពេលបច្ចុប្បន្នរបស់មេធាវីការពារក្តីពុំបានធ្វើសំណើរបៀបនេះឡើយ ហើយក៏ពុំបញ្ជាក់អំពីការជំទាស់ណាមួយទៅនឹងឯកសារជាក់លាក់ណាមួយ ឬប្រភេទនៃឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះឡើយ។

៥. អនុស្សរណៈនេះគឺជាចម្លើយជាផ្លូវការរបស់អង្គជំនុំជម្រះតបទៅនឹងឯកសារ E211 និងឯកសារ E211/1។

[3] ឯកសារ E185 , កថាខណ្ឌ ១៦ (ពាក់ព័ន្ធនឹងការដាក់ឯកសាររបស់សហព្រះរាជអាជ្ញាស្តីពីការបញ្ជាក់អំពីភាពអាចជឿជាក់បាន (ឯកសារ E158); *សូមមើលផងដែរ* ឯកសារ E185, កថាខណ្ឌ ៣០ (ដែលបានសម្រេចថាឯកសារសម័យកម្ពុជាប្រជាធិបតេយ្យដែលមជ្ឈមណ្ឌលឯកសារបានរក្សាទុកអាច "ទទួលការដេញដោលស្តីពីការសន្មតនៃភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាន *ដោយយោងតាមសេចក្តីបញ្ជាក់ដំបូងរបស់ឯកសារនោះ*")។